មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
# ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០២១-២០២៥
(ខ្លឹមសារសង្ខេប)

កាលបរិច្ឆេទអនុម័តៈ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

## អំពីផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះមានគោលបំណងកំណត់ទិសដៅសម្រាប់ ម.ស.ម.ក អនុវត្តក្នុងរយៈពេល៥ ឆ្នាំ ចាប់ពីឆ្នាំ២០២១ ដល់ ២០២៥ ដើម្បីសម្រេចនូវចក្ខុវិស័យ បេសកកម្ម និងគោលបំណងជាយុទ្ធសាស្ត្រ។

ការបង្កើតផែនការយុទ្ធសាស្ត្រនេះមានការចូលរួមពីបុគ្គលិក ម.ស.ម.ក សមាជិកក្រុមប្រឹក្សាភិបាល អង្គការសង្គមស៊ីវិលជាដៃគូជាតិ និងអន្តរជាតិ ព្រមទាំងក្រុមអ្នកទទួលផល ក្នុងដំណើរការបង្កើតផែនការយុទ្ធសាស្ត្រនេះឡើងដើម្បីប្រមូលធាតុចូលផ្សេងៗដែលធ្វើឡើងតាមរយៈការស្ទង់មតិនិងកិច្ចប្រជុំប្រឹក្សាយោបល់ផ្សេងៗជាច្រើន។

ផែនការយុទ្ធសាស្ត្រនេះ គឺជាមគ្គុទេសក៍ដែលមានលក្ខណៈបត់បែនបាន ជាជាងផែនការកំណត់នៅក្នុងបញ្ជីនោះទេ។ ទោះយ៉ាងណាក្តី ផែនការយុទ្ធសាស្ត្រនេះមានបំណងលើកឡើងនូវទិសដៅយុទ្ធសាស្ត្រដែលច្បាស់លាស់សម្រាប់ ម.ស.ម.ក អនុវត្តក្នុងរយៈពេល ៥ ឆ្នាំ តទៅមុខទៀត ស្របពេលនឹងការលើកកម្ពស់នូវគោលការណ៍តម្លាភាពនិងគណនេយ្យភាព។

ការពិនិត្យនៅពាក់កណ្តាលអាណត្តិលើផែនការយុទ្ធសាស្ត្រនេះនឹងធ្វើឡើងដើម្បីវាយតម្លៃទៅលើវិសាលភាពដែលផែនការយុទ្ធសាស្ត្រនេះនៅឆ្លើយតបទៅនឹងតម្រូវការ និងគោលបំណង ព្រមទាំងវាយតម្លៃលើការប្រែប្រួលទិដ្ឋភាពសិទ្ធិមនុស្សនៅកម្ពុជានិងដើម្បីផ្តល់ឱកាសសម្រាប់ការកែតម្រូវឱ្យស្របទៅតាមកាលៈទេសៈជាក់ស្តែង។

## សំណួរ និងមតិយោបល់

ប្រសិនបើអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីផែនការយុទ្ធសាស្ត្រនេះ ឬក៏មានបំណងផ្តល់មតិយោបល់ សូមផ្ញើសារអេឡិចត្រូនិចមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ info@cchrcambodia.org ឬទាក់ទង អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក តាមរយៈទូរស័ព្ទ +៨៥៥ (០) ១១ ៩៤៣ ២១៣ ឬ សារអេឡិចត្រូនិច ៖ chaksopheap@cchrcambodia.org។

ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចម្ការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

CC BY NC SA

# មាតិកា


អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ii

អំពីផែនការយុទ្ធសាស្ត្រ ii

និយមន័យ និងអក្សរកាត់ iv

១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា 1

១.១ ទិដ្ឋភាពទូទៅ 1

១.២ សេចក្តីសង្ខេបអំពីអភិបាលកិច្ច 1

២. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ 3

២.១ ចក្ខុវិស័យ 3

២.២ បេសកកម្ម 3

២.៣ គុណតម្លៃ 3

២.៤ និមិត្តសញ្ញា 3

២.៥ គោលបំណងនៃផែនការយុទ្ធសាស្ត្រ 3

២.៦ វិស័យការងារស្នូល 4

២. ៧ គោលដៅនៃផែនការយុទ្ធសាស្ត្រ 4

៣ .ការវិភាគលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង 7

៤. វិស័យការងារស្នូល 9

៤.១. វិស័យការងារស្នូលទី១ – ការការពារសេរីភាពមូលដ្ឋាន 9

៤.២. វិស័យការងារស្នូលទី២ – កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់ 10

៤.៣. វិស័យការងារស្នូលទី៣ – សមភាព និងការមិនរើសអើង 12

៤.៤. វិស័យការងារស្នូលទី៤ – ធុរកិច្ច និងសិទ្ធិមនុស្ស 13

៤.៥ វិស័យការងារស្នូលទី៥ – ការចូលរួមរបស់ពលរដ្ឋ និងកំណែទម្រង់ 15

៤.៦. វិស័យការងារស្នូលទី៦ – ការស្រាវជ្រាវ តស៊ូមតិ និងគោលនយោបាយ 16

# និយមន័យ និងអក្សរកាត់

| | |
|---|---|
| BHR | ធុរកិច្ច និងសិទ្ធិមនុស្ស |
| CBO | អង្គការសហគមន៍មូលដ្ឋាន |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| CFA | វិស័យការងារស្លូល |
| CNRP | គណបក្សសង្គ្រោះជាតិកម្ពុជា |
| CSO | អង្គការសង្គមស៊ីវិល |
| CPR | ការចូលរួមរបស់ពលរដ្ឋ និងកំណែទម្រង់ |
| EBA | ប្រព័ន្ធអនុគ្រោះពន្ធលើមុខទំនិញទាំងអស់ លើកលែងតែសព្វាវុធ |
| EU | សហភាពអឺរ៉ុប |
| END | សមភាព និងការមិនរើសអើង |
| FFMP | គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន |
| GSP | ប្រព័ន្ធអនុគ្រោះទូទៅ |
| GBV | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| HRD | អ្នកការពារសិទ្ធិមនុស្ស |
| ICT | បច្ចេកវិទ្យាព័ត៌មានវិទ្យា និងគមនាគមន៍ |
| ICCPR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| IFEX | បណ្តាញសកលនៃសេរីភាពខាងការបញ្ចេញមតិ |
| INGO | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| JLR | កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់ |
| LANGO | ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល |
| LGBTIQ | ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកប្តូរភេទ អន្តរភេទ និងឃ្មៀរ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoI | ក្រសួងមហាផ្ទៃ |
| MoJ | ក្រសួងយុត្តិធម៌ |
| MoWA | ក្រសួងកិច្ចការនារី |
| MoLMUPC | ក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម |
| MoLVT | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |

| | |
|---|---|
| OHCHR | ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា |
| PESTLE | នយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា ច្បាប់ និងបរិស្ថាន |
| PFF | ការពារសេរីភាពមូលដ្ឋាន |
| PFFP | គម្រោងការពារសេរីភាពមូលដ្ឋាន |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RAP | ការស្រាវជ្រាវ ការតស៊ូមតិ និងគោលនយោបាយ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SOGIESC | និន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ |
| SOGIESCP | គម្រោងនិន្នាការភេត អត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រ និង លក្ខណៈភេទ |
| SWOT | ចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង |
| UPR | ដំណើរការពិនិត្យជាសកលតាមកំណត់ |
| VGE | សំឡេងដើម្បីសមភាពយេនឌ័រ |

# ១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

## ១.១ ទិដ្ឋភាពទូទៅ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់ ការពារ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ពង្រឹងភាពអង់អាចក្លាហានដល់សង្គមស៊ីវិលដើម្បីទាមទារសិទ្ធិរបស់ខ្លួន និងការផ្លាស់ប្តូរជាវិជ្ជមានតាមរយៈការស្រាវជ្រាវស៊ីជម្រៅ និងការវិភាគ ដោយបង្កើតនូវគោលនយោបាយនវានុវត្តន៍ និងតស៊ូមតិដើម្បីអនុវត្តគោលនយោបាយនេះ។[1] ម.ស.ម.ក គឺជាសមាជិកនៃដៃគូសន្ធានអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ("IFEX") ដែលជាបណ្តាញសកលនៃសេរីភាពខាងការបញ្ចេញមតិ សម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ ("CIVICUS") និងជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្ម ("OMCT")។

ម.ស.ម.ក បាននឹងកំពុងធ្វើការងារលើការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅកម្ពុជាចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០០២។ ម.ស.ម.ក គឺជាអង្គការដំបូងដែលផ្តួចផ្តើមបង្កើតកម្មវិធីវេទិកាសាធារណៈនៅទូទាំងប្រទេសកម្ពុជាដែលជាវេទិកាមួយផ្តល់ឱកាសជូនសាធារណជនក្នុងការឈ្វេងយល់ និងសួរសំណួរពាក់ព័ន្ធនឹងសិទ្ធិរបស់ខ្លួននិងលទ្ធិប្រជាធិបតេយ្យនិងបណ្តុះបណ្តាលប្រជាពលរដ្ឋអំពីការតស៊ូមតិនិងការចងក្រងឯកសារ។

ចាប់តាំងពីពេលនោះមក ម.ស.ម.ក បានពង្រីកកម្មវិធីនានារបស់ខ្លួនរហូតមកដល់បច្ចុប្បន្នដោយផ្តោតការងារលើវិស័យសំខាន់មួយចំនួនដូចជា៖ សេរីភាពខាងការបញ្ចេញមតិ ការជួបប្រជុំ និងខាងការចងក្រងសមាគម អ្នកការពារសិទ្ធិមនុស្ស កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់ ធុរកិច្ចនិងសិទ្ធិមនុស្ស រួមមាន សិទ្ធិដីធ្លី និងធនធានធម្មជាតិ សិទ្ធិស្ត្រី និងការការពារសិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ និងអ្នកមានភេទមិនច្បាស់លាស់ ("អ្នកស្រឡាញ់ភេទដូចគ្នា")។

## ១.២ សេចក្តីសង្ខេបអំពីអភិបាលកិច្ច

ម.ស.ម.ក ត្រូវបានបង្កើតឡើងនិងបានចុះបញ្ជីជាផ្លូវការជាមួយក្រសួងមហាផ្ទៃក្នុងខែតុលា ឆ្នាំ២០០២ ដើម្បីបំពេញបេសកកម្មការងារក្នុងការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា។[2] ម.ស.ម.ក ត្រូវបានគ្រប់គ្រងអនុលោមតាមលក្ខន្តិកៈរបស់អង្គការ។[3] ម.ស.ម.ក មានក្រុមប្រឹក្សាភិបាលដែលមានសមាសភាពចូលរួមពីក្រុមបុគ្គលជោគជ័យនិងមានសក្តានុពល មានឆន្ទៈចំពោះសិទ្ធិមនុស្ស ដែលជួយគាំទ្រដល់ការងាររបស់ ម.ស.ម.ក។ ម.ស.ម.ក ធ្វើប្រតិបត្តិការប្រចាំថ្ងៃក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគ្រប់គ្រងដឹកនាំដោយអ្នកស្រី ចក់ សុភាព ដែលទទួលតួនាទីជានាយិកាប្រតិបត្តិនៅក្នុងឆ្នាំ២០១៤។ អ្នកស្រី ចក់ សុភាព គឺជាអ្នកសរសេរប្លុកដ៏មានសក្តានុពលមួយរូបនៅប្រទេសកម្ពុជា និងជាអ្នកតស៊ូមតិក្នុងវិស័យសិទ្ធិ

---

[1] ឈ្វេងយល់បន្ថែមអំពី ម.ស.ម.ក តាមរយៈ https://www.cchrcambodia.org/index_old.php?url=aboutus/aboutus.php&id=2&lang=eng%3E ។

[2] លិខិតទទួលស្គាល់ចុះបញ្ជីនៅក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ https://www.cchrcambodia.org/resource/eng/registration_eng.pdf ។

[3] លក្ខន្តិកៈរបស់ ម.ស.ម.ក ឆ្នាំ២០០២ http://www.cchrcambodia.org/resource/eng/constitution_eng.pdf។

មនុស្សដ៏លេចធ្លោផងដែរ។ ការងាររបស់អ្នកស្រី ចក់ សុភាព ត្រូវបានលោក បារ៉ាក់ អូបាម៉ា[4] អតីតប្រធានាធិបតីសហរដ្ឋអាមេរិកទទួលស្គាល់ ក៏ដូចជាសង្គមស៊ីវិល និងប្រជាពលរដ្ឋកម្ពុជាទូទៅផងដែរ។

ទំព័រទី២

[4] គេហទំព័ររបស់សេតវិមានសហរដ្ឋអាមេរិក ការិយាល័យនៃរដ្ឋលេខាធិការទទួលបន្ទុកសារព័ត៌មាន សុន្ទរកថារបស់ប្រធានាធិបតីក្នុងកម្មវិធីគំនិតផ្តួចផ្តើមសកល ប៊ីក្លីនតុន ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៤ https://www.whitehouse.gov/the-press-office/2014/09/23/remarks-president-clinton-global-initiative ។

# ២. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ

## ២.១ ចក្ខុវិស័យ

ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាពដែលពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។

## ២.២ បេសកកម្ម

បេសកកម្មរបស់ ម.ស.ម.ក គឺលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋដើម្បីផលប្រយោជន៍ដល់ពលរដ្ឋគ្រប់រូបដែលរស់នៅក្នុងប្រទេសកម្ពុជាតាមការលើកកម្ពស់ស្មារតី និងពង្រឹងភាពអង់អាចក្លាហានដល់ពលរដ្ឋឱ្យយល់ដឹងអំពីសិទ្ធិនិងតស៊ូមតិដើម្បីសិទ្ធិរបស់ខ្លួន ព្រមទាំងការពារបុគ្គលទាំងឡាយដែលសិទ្ធិរបស់ពួកគេរងការរំលោភបំពាន។

## ២.៣ គុណតម្លៃ

ម.ស.ម.ក រំពឹងថាបុគ្គលិករបស់ខ្លួន រួមទាំងអ្នកហាត់ការ និងអ្នកទទួលផលនឹងចែករំលែកនូវគុណតម្លៃពិតប្រាកដដែលឆ្លុះបញ្ចាំងនិងបំពេញបន្ថែមទៅលើចក្ខុវិស័យ បេសកកម្ម គោលបំណង និងទិសដៅ ដូចខាងក្រោម៖

1. សមភាព – យើងផ្តល់តម្លៃដល់ការចូលរួមបែបចម្រុះ ប្រឆាំងការរើសអើង និងជំរុញឱ្យមានការយល់ដឹងពីកត្តាប្រសព្វ
2. សច្ចភាព – យើងផ្តល់តម្លៃលើភាពមិនលំអៀង និងភាពស្មោះត្រង់ស្របតាមគោលការណ៍
3. សុចរិតភាព – យើងផ្តល់តម្លៃលើភាពស្មោះត្រង់ និងការប្តេជ្ញាចិត្ត
4. តម្លាភាព – យើងផ្តល់តម្លៃចំពោះការបើកចំហ និងទំនួលខុសត្រូវ
5. ភាពច្នៃប្រឌិត – យើងផ្តល់តម្លៃចំពោះគំនិតច្នៃប្រឌិតថ្មីៗ និងភាពបត់បែនក្នុងការផ្តល់ដំណោះស្រាយបែបនវានុវត្តន៍។

## ២.៤ និមិត្តសញ្ញា

និមិត្តរូបរបស់ ម.ស.ម.ក គឺ រូបសត្វស្លាបពណ៌សកំពុងហើរបំបែកចេញពីរង្វង់មូលពណ៌ផ្ទៃមេឃដែលមានន័យថាគឺជាការទាមទារសេរីភាពនៅកម្ពុជា។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

## ២.៥ គោលបំណងនៃផែនការយុទ្ធសាស្ត្រ

គោលបំណងនៃផែនការយុទ្ធសាស្ត្ររបស់ ម.ស.ម.ក បង្ហាញអំពីទិសដៅដែលត្រូវសម្រេចក្នុងរយៈពេលឆ្នាំ២០២១ - ២០២៥ រួមមាន ៖

1. លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស និងការរំលោភបំពានសិទ្ធិមនុស្សដើម្បីឱ្យពលរដ្ឋយល់ដឹងឱ្យកាន់តែប្រសើរឡើងអំពីសិទ្ធិរបស់ខ្លួន និងសិទ្ធិរបស់អ្នកដទៃ។
2. លើកកម្ពស់ស្មារតី និងបង្កឱ្យពលរដ្ឋទាំងអស់ចូលរួមឱ្យបានពេញលេញ ក្នុងនោះរួមទាំងស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា យុវជននិងក្រុមដទៃទៀតដែលពុំទាន់មានភាពជាតំណាងគ្រប់គ្រាន់។
3. ពង្រឹងភាពអង់អាចក្លាហានដល់បុគ្គល សហគមន៍ និងក្រុមងាយរងគ្រោះដើម្បីធ្វើការតស៊ូមតិទាមទារសិទ្ធិរបស់ខ្លួន។
4. ថ្កោលទោសចំពោះការរំលោភបំពានសិទ្ធិមនុស្ស និងការរើសអើងគ្រប់ទម្រង់ ព្រមទាំងលើកកម្ពស់សមភាពឱ្យបានពេញលេញ។
5. តស៊ូមតិក្នុងការទាមទារយុត្តិធម៌ ធ្វើការងារដើម្បីលុបបំបាត់ករណីនិទណ្ឌភាពទាំងអស់ និងការពារអ្នកការពារសិទ្ធិមនុស្សនិងបុគ្គលទាំងឡាយដែលសិទ្ធិរបស់ខ្លួនរងការរំលោភបំពាន។
6. តស៊ូមតិដើម្បីមានក្របខ័ណ្ឌច្បាប់មួយដែលគោរព ការពារ និងបំពេញសិទ្ធិមនុស្ស និងដើម្បីឱ្យមានការអនុវត្តក្របខ័ណ្ឌច្បាប់ឱ្យបានត្រឹមត្រូវ។

## ២.៦ វិស័យការងារស្នូល

ការងាររបស់ ម.ស.ម.ក ក្នុងរយៈពេល ឆ្នាំ២០២១-២០២៥ នឹងត្រូវបានរៀបចំទៅជាវិស័យការងារស្នូលចំនួន ៦ ("ការងារស្នូល") ដោយផ្អែកទៅតាមវិស័យការងារស្នូលពីមុន។ ទោះយ៉ាងណាក្តី មានការកែប្រែវិស័យការងារមួយចំនួនដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍក្នុងបរិបទសិទ្ធិមនុស្ស និងតម្រូវការរបស់អ្នកទទួលផល។ ការងារស្នូលមួយចំនួនត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីឆ្លើយតបនឹងការប្រែប្រួលទាំងនេះ ដូចមានគូសបញ្ជាក់ខាងក្រោម។

ការងារស្នូលទាំង ៦ ដែលមានបរិយាយពិស្តារនៅផ្នែកទី៤ រួមមាន ៖

១. ការងារស្នូលទី១ – ការការពារសេរីភាពមូលដ្ឋាន
២. ការងារស្នូលទី២ – កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់
៣. ការងារស្នូលទី៣ – សមភាព និងការមិនរើសអើង
៤. ការងារស្នូលទី៤ – ធុរកិច្ចនិងសិទ្ធិមនុស្ស
៥. ការងារស្នូលទី៥ – ការចូលរួមរបស់ពលរដ្ឋ និងកំណែទម្រង់
៦. ការងារស្នូលទី៦ – ការស្រាវជ្រាវ តស៊ូមតិ និងគោលនយោបាយ

## ២. ៧ គោលដៅនៃផែនការយុទ្ធសាស្ត្រ

ម.ស.ម.ក មានគោលដៅយុទ្ធសាស្ត្រចំនួនបួន។ ទាំងនេះជាការរំពឹងលទ្ធផលកម្រិតខ្ពស់ដែលផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់អនុវត្តគម្រោង និងសកម្មភាពនានារបស់ ម.ស.ម.ក ។ ទិសដៅយុទ្ធសាស្ត្រទាំងនេះមានដូចជា ៖

១. ពង្រីក និងពង្រឹងលម្ហសម្រាប់ពលរដ្ឋ
២. អប់រំ និងពង្រឹងភាពអង់អាចក្លាហាន
៣. ការពារប្រឆាំងនឹងការរំលោភបំពានសិទ្ធិមនុស្ស
៤. ស្រាវជ្រាវ វិភាគ និងតស៊ូមតិ

*រូបភាពទី ១ បង្ហាញនូវក្របខ័ណ្ឌដែលបញ្ចូលគោលដៅយុទ្ធសាស្ត្រភ្ជាប់ទំនាក់ទំនងទៅនឹងគោលបំណងយុទ្ធសាស្ត្រពាក់ព័ន្ធដែលបង្ហាញអំពីការងាររបស់ ម.ស.ម.ក។*

រូបភាពទី ១ ៖ គោលដៅយុទ្ធសាស្ត្រ និងគោលបំណង




គោលដៅទាំងនេះមានទំនាក់ទំនងនឹងវិស័យការងារស្នូល។ ការរួមចំណែកនៃវិស័យការងារស្នូលនីមួយៗជួយឱ្យសម្រេចគោលដៅនានាមានបរិយាយពិស្តារនៅផ្នែកទី៤។ ខាងក្រោមនេះបរិយាយដោយសង្ខេបអំពីវិធីដែល ម.ស.ម.ក អនុវត្តការងារដើម្បីសម្រេចនូវគោលដៅនីមួយៗ។

### *២.៧.១ ពង្រីក និងពង្រឹងលម្ហសម្រាប់ពលរដ្ឋ*

ម.ស.ម.ក នឹងលើកកម្ពស់ការយល់ដឹងក្នុងចំណោមពលរដ្ឋនៅកម្ពុជាអំពីបញ្ហាសិទ្ធិមនុស្សតាមរយៈសមាហរណកម្មយុទ្ធសាស្ត្រដែលបង្កើតវិធីសម្រាប់អនុវត្តបន្ថែមជាច្រើនជាពិសេសក្នុងវិស័យការងារស្នូលទី៥។

គោលដៅក្រុមអ្នកទទួលផលគឺជាពលរដ្ឋកម្ពុជាទូទៅ ហើយក៏រាប់បញ្ចូលក្រុមមួយចំនួនផ្សេងទៀតដែលមានតម្រូវការក្នុងការទទួលបានព័ត៌មានជាក់លាក់ផងដែរដូចជា ស្ត្រី យុវជន អ្នកស្រឡាញ់ភេទដូចគ្នា បុគ្គលដែលរងផលប៉ះពាល់ដោយធុរកិច្ចនិងសិទ្ធិមនុស្ស ព្រមទាំងក្រុមផ្សេងទៀតដែលខ្វះភាពជាតំណាងរបស់ខ្លួន។

### *២.៧.២ ការអប់រំ និងការពង្រឹងភាពអង់អាចក្លាហាន*

ការអប់រំ និងការពង្រឹងភាពអង់អាចក្លាហាននឹងនៅតែជាវិស័យស្នូលដោយគម្រោងជាច្រើនអនុវត្តសកម្មភាពដែលមានការចូលរួមពីសហគមន៍ ក្រោមការងារស្នូលទី២ ការងារស្នូលទី៣ និងការងារស្នូលទី៤។

គម្រោងអនុវត្តសកម្មភាពផ្ទាល់ជាមួយសហគមន៍មូលដ្ឋានតាមរយៈការផ្តល់ការគាំទ្រយ៉ាងទូលំទូលាយដល់សហគមន៍ដែលរងការរំលោភបំពានសិទ្ធិមនុស្ស។ ម.ស.ម.ក នឹងកសាងទំនាក់ទំនងរយៈពេលយូរអង្វែងជាមួយសហគមន៍គោលដៅមួយចំនួន ហើយពេលខ្លះនឹងធ្វើកិច្ចសហការក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលផ្សេងៗដែលអាចផ្តល់សេវានានាបន្ថែមទៀត។

### ២.៧.៣ ការការពារប្រឆាំងការរំលោភបំពានសិទ្ធិមនុស្ស

យន្តការការពារអ្នកការពារសិទ្ធិមនុស្ស នឹងបន្តផ្តល់ការគាំទ្រផ្នែកច្បាប់ សន្តិសុខ មនុស្សធម៌ និងផ្លូវចិត្ត ក៏ដូចជាការតស៊ូមតិផ្អែកទៅតាមករណី សម្រាប់អ្នកការពារសិទ្ធិមនុស្សក្រោមវិស័យការងារស្នូលទី១ គឺការការពារសេរីភាពមូលដ្ឋាន។ ចំនួននិងប្រភេទនៃការផ្តល់ការគាំទ្រដល់អ្នកការពារសិទ្ធិមនុស្សអាចនឹងមានបន្ថែម ព្រោះស្ថានភាពសិទ្ធិមនុស្សកំពុងស្ថិតក្រោមការគំរាមកំហែងកាន់តែខ្លាំងឡើងៗ ហើយលម្ហនៃការចូលរួមរបស់ពលរដ្ឋកាន់តែតូចចង្អៀតទៅៗ។ អ្នកការពារសិទ្ធិមនុស្ស និងបុគ្គលដែលសិទ្ធិរបស់ពួកគេរងការរំលោភបំពានក្រោមវិស័យការងារស្នូលផ្នែកសមភាពយេនឌ័រ និងការមិនរើសអើង ធុរកិច្ចនិងសិទ្ធិមនុស្ស ហើយនិងការពារសេរីភាពមូលដ្ឋាន នឹងស្ថិតក្រោមការគាំទ្រពីយន្តការការពារអ្នកការពារសិទ្ធិមនុស្ស។

### ២.៧.៤ ការស្រាវជ្រាវ តស៊ូមតិ និងគោលនយោបាយ

ការស្រាវជ្រាវ និងការវិភាគដើម្បីគាំទ្រដល់ការតស៊ូមតិផ្អែកលើភ័ស្តុតាង ហើយនិងគោលនយោបាយ គឺស្ថិតនៅជួរមុខ និងជាការងារដ៏សំខាន់របស់ ម.ស.ម.ក ស្ថិតក្រោមវិស័យការងារស្នូលទី៦ (ការស្រាវជ្រាវ វិភាគ និងតស៊ូមតិ)។

វិស័យនេះមានសារៈសំខាន់ព្រោះថាការតស៊ូមតិរបស់ ម.ស.ម.ក គឺផ្អែកទៅលើការស្រាវជ្រាវនិងការវិភាគដែលសំអាងលើករណីជាក់ស្តែងសម្រាប់ឱ្យអ្នកតាក់តែងគោលនយោបាយទទួលយក ក្នុងនោះរួមទាំងមន្ត្រីរដ្ឋាភិបាលផងដែរ។ ករណីនេះនៅតែមានសារៈសំខាន់ក្នុងការបញ្ជាក់ពីការមិនពាក់ព័ន្ធនឹងសកម្មភាពនយោបាយ និងគោលជំហាងករាជ្យរបស់ ម.ស.ម.ក ។

ចំណុចសំខាន់ខ្លាំងមួយផងដែរទាក់ទងនឹងការរក្សាទំនាក់ទំនងជាមួយអង្គការថ្នាក់តំបន់ និងអង្គការអន្តរជាតិ ព្រមទាំងយន្តការសិទ្ធិមនុស្សនានា។ ក្នុងនោះការសម្របសម្រួលឱ្យមានការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការពិនិត្យជាសកលតាមកាលកំណត់ («យូភីអ») នឹងនៅតែបន្ត។

## ៣ .ការវិភាគលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង

ការវិភាគលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង (SWOT) សម្រាប់ ម.ស.ម.ក ផ្អែកលើគំនិតនានាដែលទទួលបានពីកិច្ចប្រជុំប្រឹក្សាយោបល់ ការពិភាក្សាជាមួយក្រុមគោលដៅ និងការរៀបចំសិក្ខាសាលាដើម្បីកំណត់លទ្ធភាពសួលរបស់ ម.ស.ម.ក និងតម្រង់ទិសដៅឱ្យស្របជាមួយកត្តាជោគជ័យខាងក្រៅ និងដើម្បីដោះស្រាយចំណុចខ្សោយ និងការគំរាមកំហែង។

**តារាងទី១ លើកឡើងសង្ខេបអំពីចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង។**

*តារាងទី១ ៖ ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង*

| ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង | |
|---|---|
| *ចំណុចខ្លាំង* | *ចំណុចខ្សោយ* |
| • ការជឿជាក់ពីម្ចាស់ជំនួយនិងសហគមន៍សិទ្ធិមនុស្ស<br>• តស៊ូមតិផ្អែកលើភ័ស្តុតាងដោយប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន ការស្រាវជ្រាវ និងការវិភាគ<br>• ទំនាក់ទំនងរវាងការការពារ តស៊ូមតិ និងយន្តការការពារអ្នកការពារសិទ្ធិមនុស្ស<br>• គុណភាពនៃកម្មវិធីនានា<br>• អប់រំ និងពង្រឹងសមត្ថភាពអ្នកទទួលផល ដូចជាស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា បុគ្គលដែលរងផលប៉ះពាល់ដោយសារទំនាស់ដីធ្លី ជនជាតិដើមភាគតិច និងកម្មករ<br>• សង្កេតការណ៍សវនាការ<br>• សហការក្នុងភាពជាដៃគូរឹងមាំ ដូចជា ជាមួយអង្គការអន្តរជាតិ ស្ថានទូត និងអង្គការសង្គមស៊ីវិលក្នុងស្រុកជាដើម<br>• គោលនយោបាយផ្ទៃក្នុង និងរចនាសម្ពន្ធការងារច្បាស់លាស់និងប្រកបដោយប្រសិទ្ធភាព<br>• ការពង្រឹងសមត្ថភាព និងការថែទាំសុខុមាលភាពបុគ្គលិក<br>• បុគ្គលិកមានបទពិសោធន៍ និងសមត្ថភាព<br>• ស្ថិរភាពនៃហិរញ្ញវត្ថុតាមរយៈការគាំទ្រពីម្ចាស់ជំនួយផ្សេងៗច្រើន | • ការស្គាល់ ម.ស.ម.ក របស់សាធារណជន លើកលែងតែសហគមន៍សិទ្ធិមនុស្ស នៅមានកម្រិត<br>• វិសាលភាពនៃការលើកកម្ពស់ការយល់ដឹងដល់សាធារណៈជនគួរពង្រីកបន្ថែម ហើយសម្រាប់កម្មវិធីវិទ្យុដែលចាំបាច់ត្រូវកែលម្អឱ្យមានប្រសិទ្ធភាពថែមទៀត<br>• ការបំពេញសកម្មភាពការងារទៅដល់សហគមន៍ដាច់ស្រយាលនៅមានកម្រិត ព្រោះមានការិយាល័យតែមួយនៅរាជធានីភ្នំពេញ<br>• លំបាកក្នុងការទទួលបានកិច្ចសហការ និងការគាំទ្រពីអាជ្ញាធរសម្រាប់ការងារតស៊ូមតិនៅថ្នាក់មូលដ្ឋាន<br>• ការផ្តល់ជំនួយផ្នែកច្បាប់ភាគច្រើនសម្រាប់តែករណីព្រហ្មទណ្ឌ មិនមែនករណីរដ្ឋប្បវេណី ដោយសារទំហំមូលនិធិមានកំណត់<br>• ប្រឈមនឹងបញ្ហាអសន្តិសុខពេលធ្វើដំណើរទៅកាន់ខេត្ត ដូចជា ត្រូវជិះរថយន្តឈ្នួលជាដើម<br>• ពឹងផ្អែកទាំងស្រុងលើការគាំទ្រថវិកាពីម្ចាស់ជំនួយ និងមានម្ចាស់ជំនួយតិចតួចប៉ុណ្ណោះដែលមានបំណងផ្តល់ជំនួយសម្រាប់ចំណាយលើប្រតិបត្តិការទូទៅ<br>• ម្ចាស់ជំនួយផ្តល់មូលនិធិដល់វិស័យការងារតែមួយចំនួន ដូចជាដំណើរការសំខាន់ៗ |

## ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង

| *កាលានុវត្តភាព* | *ការគំរាមកំហែង* |
|---|---|
| • មានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលនឹងបង្កលក្ខណៈកាន់តែងាយស្រួលដល់ការតស៊ូមតិ<br>• ពង្រីកវិសាលភាពអ៊ីនធឺណិតបន្ថែម ដោយប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការងាររបស់ ម.ស.ម.ក<br>• ធ្វើសកម្មភាពនៅលើបណ្ដាញអ៊ីនធឺណិតបន្ថែមទៀត ដូចជាការបណ្ដុះបណ្ដាល<br>• ពង្រីកលម្ហនៃការចូលរួមរបស់ពលរដ្ឋលើប្រព័ន្ធ អ៊ីនធឺណិតសម្រាប់ការពិភាក្សានិងសន្ទនាអំពីសិទ្ធិមនុស្ស ច្បាប់និងផលប៉ះពាល់<br>• ការតស៊ូមតិផ្នែកគោលនយោបាយអំពីច្បាប់ជាមួយដៃគូដែលធ្វើការងារក្នុងវិស័យដូចគ្នា រួមទាំងតួអង្គនៅថ្នាក់តំបន់ និងអន្តរជាតិ<br>• ការវាយតម្លៃហានិភ័យដើម្បីការពារអ្នកការពារសិទ្ធិមនុស្សដែលប្រើប្រាស់អ៊ីនធឺណិត<br>• សិទ្ធិរបស់យុវជននឹងកើនឡើងខ្លាំង ស្របពេលដែលលំហូនៃការចូលរួមតូចចង្អៀត បង្កើតវិធីបែបនវានុវត្តន៍ដើម្បីបង្កើនការចូលរួមរបស់យុវជន<br>• រក្សាទំនាក់ទំនងជាមួយអង្គការអន្តរជាតិ និងប្រើប្រាស់យន្តការអន្តរជាតិ<br>• ប្រកាន់គោលជំហរច្បាស់លាស់ជាមួយដៃគូ និងផ្ដល់ការគាំទ្រនូវព័ត៌មានត្រឹមត្រូវ<br>• ការបោះឆ្នោតឃុំ/សង្កាត់ និងការបោះឆ្នោតថ្នាក់ជាតិក្នុងឆ្នាំ២០២៣ និងភាពមិនប្រាកដប្រជាជុំវិញបរិបទនយោបាយទាក់ទងនឹងការបោះឆ្នោត។ | • ការគ្រប់គ្រងអំណាចកើនឡើង ហើយលទ្ធិប្រជាធិតេយ្យធ្លាក់ចុះ<br>• ការដកប្រព័ន្ធអនុគ្រោះពន្ធលើមុខទំនិញទាំងអស់លើកលែងតែសព្វាវុធ( EBA )នឹងប៉ះពាល់ដល់ទៅលើហិរញ្ញវត្ថុ<br>• ជំងឺកូវីដ-១៩ តម្រូវឲ្យមានជីវភាពរស់នៅប្រកបដោយប្រយ័ត្នប្រយែង<br>• ការឃ្លាំមើលបណ្ដាញផ្សព្វផ្សាយសង្គមមានការកើនឡើង<br>• ការគំរាមកំហែងខ្លាំងលើសកម្មជនអ៊ីនធឺណិត<br>• អាជ្ញាធរអាចនឹងឃ្លាំមើលសកម្មភាពរបស់ពលរដ្ឋ<br>• ការបង្កើតច្បាប់ច្រើនប៉ះពាល់ខ្លាំងលើសិទ្ធិមនុស្ស<br>• រដ្ឋាភិបាលចោទប្រកាន់បទព្រហ្មទណ្ឌលើការអនុវត្តសេរីភាពខាងការបញ្ចេញមតិ<br>• សមត្ថភាពក្នុងការវិភាគឱ្យបានស៊ីជម្រៅទៅលើច្បាប់នានានៅមានកម្រិត<br>• ការដាក់កំហិតខ្លួនឯងនៅលើប្រព័ន្ធផ្សព្វផ្សាយ<br>• ម្ចាស់ជំនួយអាចនឹងបន្ថយការចូលរួម តែយ៉ាងណាក្ដីសិទ្ធិមនុស្សជាប្រធានបទសំខាន់ថ្នាក់តំបន់ដែលអាចទាញចំណាប់អារម្មណ៍ថែមទៀតពីម្ចាស់ជំនួយ។ |

# ៤. វិស័យការងារស្នូល

## ៤.១. វិស័យការងារស្នូលទី១ – ការការពារសេរីភាពមូលដ្ឋាន

### *៤.១.១. គោលដៅ លទ្ធផល និងសកម្មភាព*

គោលដៅរួមក្នុងវិស័យការងារស្នូលទី១ គឺ ៖

- ពលរដ្ឋអាចអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួនដោយគ្មានការព្រួយបារម្ភ ឬការធ្វើទុក្ខបុកម្នេញ។

ម.ស.ម.ក មានបំណងសម្រេចនូវលទ្ធផលខាងក្រោម តាមការអនុវត្តសកម្មភាពក្រោមវិស័យស្នូលការពារសេរីភាពមូលដ្ឋាននោះ គឺ ៖

- រដ្ឋាភិបាលគោរពសេរីភាពមូលដ្ឋានបានប្រសើរ
- មានទំនួលខុសត្រូវខ្ពស់ និងផ្តល់សំណងចំពោះការរំលោភបំពានលើសេរីភាពមូលដ្ឋាននានា
- អ្នកការពារសិទ្ធិមនុស្ស និងជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សទទួលបានការការពារ។

ការងារស្នូលទាក់ទងនឹងការការពារសេរីភាពមូលដ្ឋាននឹងបន្តលើកឡើងនៅក្នុងវិស័យការងារស្នូលទី១។ តែយ៉ាងណាក្តី ម.ស.ម.ក មានបំណងពង្រីក និងពង្រឹងយន្តការការពារអ្នកការពារសិទ្ធិមនុស្ស ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលតាមតម្រូវការជាក់ស្តែង ស្របទៅតាមទំហំមូលនិធិដែលខ្លួនមាន។

- *សកម្មភាព ១.១. កំណត់ឱ្យបានច្បាស់ចំពោះអ្នកទទួលផល ដែលជាអ្នកការពារសិទ្ធិមនុស្ស និងបុគ្គលផ្សេងទៀតដែលនឹងត្រូវទទួលបានការការពារ*

  ម.ស.ម.ក នឹងកំណត់ឱ្យបានច្បាស់លាស់ចំពោះអ្នកការពារសិទ្ធិមនុស្ស និងបុគ្គលផ្សេងទៀតដែលនឹងត្រូវទទួលបានការគាំទ្រតាមរយៈយន្តការការពារអ្នកការពារសិទ្ធិមនុស្ស ដើម្បីធានាថាការគាំទ្រនោះឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងបន្ទាន់ ព្រមទាំងប្រកបដោយគុណភាពនិងប្រសិទ្ធភាព។

- *សកម្មភាព ១.២. ការឆ្លើយតបយ៉ាងសមស្រប ដោយអនុវត្តនីតិវិធីផ្អែកលើភ័ស្តុតាង តាមយន្តការមួយឆាប់រហ័ស*

  ម.ស.ម.ក នឹងបន្តអនុវត្តរបៀបនៃការធ្វើសេចក្តីសម្រេចដោយតម្លាភាព និងតម្រូវឱ្យមានភ័ស្តុតាងដើម្បីកំណត់ថាតើអាចផ្តល់ជំនួយក្រោមយន្តការការពារអ្នកការពារសិទ្ធិមនុស្សដែរឬយ៉ាងណា។ ម.ស.ម.ក នឹងប្រើប្រាស់យន្តការឆ្លើយតបឆាប់រហ័សសម្រាប់ករណីបន្ទាន់។ ម.ស.ម.ក ក៏នឹងសម្របសម្រួលជាមួយអង្គការសង្គមស៊ីវិលផ្សេងទៀតផងដែរដើម្បីធានាថាការគាំទ្របន្ទាន់នោះពិតជាបានទៅដល់គោលដៅ និងមិនត្រួតគ្នា។

- *សកម្មភាព ១.៣. ការអនុវត្តយុទ្ធសាស្ត្រតាំងផ្លូវច្បាប់*

  ម.ស.ម.ក នឹងអនុវត្តយុទ្ធសាស្ត្រតាំងផ្លូវច្បាប់ក្នុងករណីដែលខ្លួនយល់ថាអាចនឹងមានផលជះបែបយុទ្ធសាស្ត្រលើបញ្ហាសិទ្ធិមនុស្ស។

- *សកម្មភាព ១.៤. ការពង្រឹងប្រសិទ្ធភាពនៃការគាំទ្រ*

  ម.ស.ម.ក មានក្រុមមេធាវីសម្រាប់ផ្តល់ជំនួយផ្លូវច្បាប់ ដែលនេះគឺជាការផ្តល់ការឆ្លើយតបមានលក្ខណៈបត់បែននិងមានប្រសិទ្ធភាព។

ដើម្បីបង្កើនអត្ថប្រយោជន៍គាំទ្រជំនួយផ្នែកផ្លូវចិត្ត បុគ្គលិក ម.ស.ម.ក នឹងទទួលបានការបណ្តុះបណ្តាលអំពីៈ

- ការកំណត់សម្គាល់លើសញ្ញានានាដែលត្រូវផ្តល់ជំនួយផ្លូវចិត្ត
- ដឹងពីប្រភេទនៃជំនួយខុសគ្នាៗទៅតាមជម្រើសផ្សេងៗ ដូចជា ក្នុងសហគមន៍ មណ្ឌលសុខភាពសាធារណៈ មណ្ឌលសុខភាពឯកជន និងមណ្ឌលថែទាំសុខភាពរបស់អង្គការដៃគូ។

  ម្យ៉ាងទៀត សម្រាប់ដៃគូដែលផ្តល់ជំនួយផ្លូវចិត្តដល់អ្នកការពារសិទ្ធិមនុស្សនឹងតម្រូវឱ្យពន្យល់ពីគោលបំណងក្នុងការបង្កើនប្រសិទ្ធភាពលើការផ្តល់សេវារបស់ពួកគេទៅតាមទំហំកញ្ចប់ថវិកា។

- *សកម្មភាព ១.៥. បង្កើនឱ្យមានការគាំទ្រពីស្ថាប័នទទួលខុសត្រូវ*

  ប្រាកដណាស់ថាក្នុងករណីខ្លះ ម.ស.ម.ក ចាំបាច់ឱ្យអាជ្ញាធរមានសមត្ថកិច្ចចូលរួមដើម្បីៈ

  - ពន្យល់អាជ្ញាធរអំពីកាតព្វកិច្ចរបស់ពួកគេក្រោមច្បាប់អន្តរជាតិ និងច្បាប់ជាតិ
  - កសាងសមត្ថភាព ចំណេះដឹង និងជំនាញដល់ពួកគេ ក្នុងការប្រតិបត្តិច្បាប់ និងការពារអ្នកការពារសិទ្ធិមនុស្ស និងបុគ្គលដែលសិទ្ធិរបស់ពួកគេរងការរំលោភបំពាន។

- *សកម្មភាព ១.៦. លើកកម្ពស់ការយល់ដឹងអំពីការរំលោភបំពានលើសេរីភាពមូលដ្ឋាន*

  សកម្មភាពនេះស្របទៅនឹងគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន និងគោលដៅទីបីនៃគម្រោងការពារសេរីភាពមូលដ្ឋាន។ គម្រោងទាំងនេះនឹងនៅតែបន្ត ព្រោះផ្តល់ភស្តុតាងជាមូលដ្ឋានសំខាន់សម្រាប់ការតស៊ូមតិ។

## ៤.២. វិស័យការងារស្នូលទី២ – កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់

### *៤.២.១ គោលដៅ លទ្ធផល និងសកម្មភាព*

គោលដៅរួមនៃវិស័យការងារស្នូលទី២ គឺៈ

- ដើម្បីឱ្យមានប្រព័ន្ធយុត្តិធម៌រឹងមាំ និងប្រសិទ្ធភាព ដែលការពារនីតិរដ្ឋស្របទៅតាមកាតព្វកិច្ចរបស់កម្ពុជាក្នុងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន

ក្រោមវិស័យការងារស្នូលទី២ ម.ស.ម.ក មានគោលបំណងសម្រេចឱ្យបាននូវលទ្ធផលដូចខាងក្រោមៈ

- ពង្រឹងការអនុវត្តច្បាប់ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌
- ច្បាប់នានាស្របជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ
- បង្កើនការយល់ដឹងអំពីច្បាប់ដែលពាក់ព័ន្ធដល់ស្ថាប័នតុលាការ

- សកម្មភាព ២.១. ពង្រីកការសង្កេតការណ៍សវនាការបន្ថែមទៅដល់ខេត្តមួយចំនួនផ្សេងទៀត

  ដោយសារមានការបង្កើតសាលាឧទ្ធរណ៍នៅក្នុងខេត្តព្រះសីហនុ ត្បូងឃ្មុំ និងបាត់ដំបង ម.ស.ម.ក មានគោលបំណងពង្រីកការសង្កេតការណ៍សវនាការបន្ថែមទៅដល់ខេត្តទាំងនោះ។

- *សកម្មភាព ២.២. បង្កើនផ្តោតការយកចិត្តទុកដាក់លើបញ្ហាច្បាប់សំខាន់ៗ*

  ការសង្កេតការណ៍សវនាការគឺប្រើប្រាស់ពេលវេលា និងធនធានជាច្រើន។ ដោយសារធនធានមានចំនួនកំណត់ ប្រភេទករណីខ្លះដែលអាចឱ្យមានការផ្តល់អនុសាសន៍លើបញ្ហាផ្នែកនីតិវិធី និងបញ្ហាសំខាន់ៗជួយបង្កើនផលជះយ៉ាងច្រើន។

ម.ស.ម.ក នឹងបន្តសង្កេតការណ៍សវនាការក្នុងសំណុំរឿងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ម.ស.ម.ក ក៏នឹងពិចារណាក្នុងការសង្កេតការណ៍សវនាការលើករណីផ្សេងទៀតស្របជាមួយបេសកម្មនិងចក្ខុវិស័យផងដែរ។

- *សកម្មភាព ២.៣.បង្កើនការចូលរួមជាមួយរដ្ឋាភិបាលដើម្បីបង្កើនផលជះ*

កិច្ចប្រជុំពិគ្រោះយោបល់រវាង ម.ស.ម.ក និងរដ្ឋាភិបាលនឹងបន្តពិភាក្សាលើលទ្ធភាពក្នុងការបញ្ចូលការសង្កេតការណ៍សវនាការបន្ថែមទៅដល់សាលាឧទ្ធរណ៍ថ្មីៗ ហើយនឹងពិភាក្សាអំពីរបកគំហើញ និងអនុសាសន៍។ ទោះយ៉ាងណាក្តី តុលាការអាចផ្តល់ជាតុចូល ចំណែកឯ ម.ស.ម.ក នឹងនៅតែជាអ្នកទទួលខុសត្រូវលើការផលិតរបាយការណ៍។

ម.ស.ម.ក ក៏នឹងចូលរួមជាមួយក្រសួងដែលមានទំនួលខុសត្រូវចម្បងលើច្បាប់ដែលទាក់ទងនឹងករណីកំពុងសង្កេតការណ៍។

- *សកម្មភាព ២.៤. ការផ្តល់ការគាំទ្រក្នុងសំណុំរឿងរដ្ឋប្បវេណី*

បច្ចុប្បន្ននេះ ម.ស.ម.ក អាចផ្តល់ជំនួយមេធាវីដល់បុគ្គលដែលសិទ្ធិរបស់ពួកគេរងការរំលោភបំពាន និងបុគ្គលដែលប្រឈមនឹងការជំនុំជម្រះផ្នែកព្រហ្មទណ្ឌ។ ប៉ុន្តែ ប្រសិនបើម្ចាស់ជំនួយនៅបន្តផ្តល់មូលនិធិ ម.ស.ម.ក នឹងពង្រីកការគាំទ្របន្ថែមនៅក្នុងសំណុំរឿងរដ្ឋប្បវេណី។

- *សកម្មភាព ២.៥. ការពង្រីកកម្មវិធីបំពាក់បំប៉នដល់យុវជនដើម្បីបង្កើនផលជះ និងនិរន្តរភាពនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌*

កម្មវិធីវគ្គបំពាក់បំប៉នដល់យុវជនបច្ចុប្បន្នកំពុងកំណត់គោលដៅលើនិស្សិតច្បាប់។ កម្មវិធីនេះនឹងពង្រីកបន្ថែមដល់និស្សិតដែលសិក្សាលើមុខវិជ្ជាផ្សេងៗ។

កម្មវិធីបច្ចុប្បន្នទទួលបានមតិគាំទ្រយ៉ាងខ្លាំងពីអ្នកចូលរួមទាក់ទងនឹងការលើកកម្ពស់ការយល់ដឹង និងមានការចាប់អារម្មណ៍លើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ និងច្បាប់។

- *សកម្មភាព ២.៦. បន្តបង្កើនចំណេះដឹងអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងវិធីសាស្ត្រក្នុងការសង្កេតការណ៍សវនាការ*

ម.ស.ម.ក នឹងបន្តរៀបចំ និងសម្របសម្រួលកម្មវិធីសិក្ខាសាលាបង្កើនសមត្ថភាពអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងវិធីសាស្ត្រក្នុងការសង្កេតការណ៍សវនាការសម្រាប់អង្គការសង្គមស៊ីវិលនិស្សិត ហើយនិងអ្នកពាក់ព័ន្ធក្នុងវិស័យតុលាការ។

- *សកម្មភាព ២.៧. លើកកម្ពស់ការយល់ដឹង និងជំរុញឱ្យមានការចាប់អារម្មណ៍លើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងច្បាប់*

ម.ស.ម.ក នឹងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជនតាមរយៈការផ្តល់គំនិត និងជំនាញ ហើយនិងការសម្របសម្រួលក្នុងវិស័យការងារស្នូលទី៥ ដើម្បីសម្រេចដល់ក្រុមគោលដៅឱ្យបានទូលំទូលាយ។

## ៤.៣. វិស័យការងារស្នូលទី៣ – សមភាព និងការមិនរើសអើង

### *៤.៣.១. គោលដៅ លទ្ធផល និងសកម្មភាព*

គោលដៅរួមនៅក្នុងវិស័យការងារស្នូលទី៣ គឺៈ

- បុគ្គល ឬក្រុមងាយរងគ្រោះទទួលបានសិទ្ធិមនុស្សពេញលេញ និងស្មើភាពគ្នា។

ការអនុវត្តវិស័យការងារស្នូលទី៣ នាំឱ្យសម្រេចបាននូវលទ្ធផលដូចខាងក្រោម ៖

- សាធារណជនយល់ដឹងអំពីសិទ្ធិរបស់ក្រុមងាយរងគ្រោះ និងគ្មានមានការរើសអើង
- បុគ្គល ឬក្រុមងាយរងគ្រោះទទួលបានការពង្រឹងភាពអង់អាចក្លាហានក្នុងការអនុវត្តសិទ្ធិ និងតស៊ូមតិទាមទារសិទ្ធិរបស់ខ្លួន
- អាជ្ញាធររដ្ឋាភិបាលបំពេញតួនាទីរបស់ខ្លួនក្នុងការការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះ
- មានសមភាពផ្លូវច្បាប់សម្រាប់ក្រុមងាយរងគ្រោះ។

- *សកម្មភាព ៣.១. បន្តអាទិភាពលើការបញ្ជ្រាបសិទ្ធិរបស់ស្ត្រី និងសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា*

  ក្នុងករណីមានលទ្ធភាពអាចធ្វើទៅបាន គម្រោងនានារបស់ ម.ស.ម.ក នឹងកំណត់ជ្រើសរើសស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាក្នុងចំណោមអ្នកទទួលផលសំខាន់ៗរបស់គម្រោង ហើយនឹងបង្កើតសកម្មភាពនានាដើម្បីទទួលបានលទ្ធផលជាក់លាក់ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។ ម.ស.ម.ក នឹងបន្តបណ្តុះបណ្តាលចំណេះដឹងបន្ថែមដល់អ្នកសម្របសម្រួលគម្រោង និងបុគ្គលិកឱ្យបានយល់ច្បាស់លើបញ្ហាដែលប្រឈមរបស់ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នា ព្រមទាំងការឆ្លើយតបឱ្យបានសមស្រប។

- *សកម្មភាព ៣.២. ការបង្កើនផលជះជាអតិបរមាផ្នែកការអប់រំ និងសកម្មភាពពង្រឹងភាពអង់អាចក្លាហាន*

  វិស័យការងារស្នូលទី ៣ នឹងផ្តោតទៅលើ ៖

  - ការបង្កើនចំណេះដឹងអំពីសិទ្ធិមនុស្សដល់បុគ្គល ឬសហគមន៍ងាយរងគ្រោះ ហើយនិងរបៀបនៃការដោះស្រាយបញ្ហាប្រឈម
  - ពង្រឹងភាពអង់អាចក្លាហានដល់បុគ្គលទាំងឡាយដែលសិទ្ធិរបស់ពួកគេរងការរំលោភបំពានដើម្បីអាចធ្វើការតស៊ូមតិបានដោយខ្លួនឯង ឧទាហរណ៍ ជាមួយអាជ្ញាធរ និយោជក ឬក្រុមហ៊ុនសាជីវកម្មជាដើម។

  ចំណុចស្នូលនៃវិធីសាស្ត្រនេះនឹងគាំទ្រដល់ការសិក្សា ការចូលរួម និងសកម្មភាពចងក្រងបណ្តាញដែលអ្នកទទួលផលអាចបង្កើតជំនាញ និងចំណេះដឹងក្នុងការតស៊ូមតិសម្រាប់ខ្លួនពួកគាត់ផ្ទាល់ និងដើម្បីគាំទ្រដល់សហគមន៍ឱ្យបានទូលំទូលាយ។

  ដើម្បីបង្កើនផលជះជាអតិបរមា ម.ស.ម.ក នឹងកំណត់គោលដៅលើអ្នកទទួលផលមួយចំនួនដែលប្រឈមនឹងការគំរាមកំហែងជាក់លាក់ដើម្បីសិក្សានិងចូលរួមក្នុងសកម្មភាពនានា។

- *សកម្មភាព ៣.៣. រក្សាភាពជាដៃគូដើម្បីបង្កើតលទ្ធផលប្រកបដោយប្រសិទ្ធភាពនៅកម្រិតសហគមន៍*

ម.ស.ម.ក នឹងបន្តសហការជាមួយអង្គការសង្គមស៊ីវិលដែលធ្វើសកម្មភាពផ្ទាល់នៅថ្នាក់មូលដ្ឋាន ពង្រឹងទំនាក់ទំនងជាមួយសហគមន៍ និងផ្តល់សេវានានាបន្ថែម។

- *សកម្មភាព ៣.៤. ការចូលរួមជាមួយរដ្ឋាភិបាល*

សារៈសំខាន់នៅត្រង់ចំណុចនេះគឺការបង្កើតមធ្យោបាយនៃការធ្វើទំនាក់ទំនងបន្ថែមទៀតជាមួយរដ្ឋាភិបាលដើម្បីបង្កើនប្រសិទ្ធភាពនៃការងារ។

- *សកម្មភាព ៣.៥. ការអប់រំ និងការពង្រឹងភាពអង់អាចក្លាហាន*

ម.ស.ម.ក នឹងអប់រំ និងពង្រឹងភាពអង់អាចក្លាហានដល់ភាគីទាំងអស់ដែលចូលរួមក្នុងកិច្ចការងារផ្នែកសិទ្ធិស្ត្រីនិងអ្នកស្រឡាញ់ភេទដូចគ្នា។ អ្នកទទួលផលបឋមនោះគឺ ស្ត្រីនិងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

បន្ថែមលើនេះ វិធីសាស្ត្រគៀរគរឱ្យមានការចូលរួមពីភាគីច្រើនក្នុងនោះរួមទាំងរដ្ឋាភិបាល ក្រុមហ៊ុននិងអង្គការសង្គមស៊ីវិលផ្សេងៗ សមាជិកសហគមន៍ងាយរងគ្រោះ និងភាគីពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នឹងនាំឱ្យសម្រេចនូវទិសដៅនិងលទ្ធផលក្នុងវិស័យការងារស្នូលទី៣ តាមរយៈការដោះស្រាយបញ្ហានៅតាមវេទិកាសាធារណៈនានា ដូចជា ៖

  - បញ្ហាសិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងសហគមន៍ និងភាគីដទៃទៀតនាពេលនោះ
  - សារៈសំខាន់នៃការចូលរួមក្នុងលម្ហសម្រាប់ពលរដ្ឋអនុវត្តសេរីភាពនិងតម្រូវការក្នុងការទាមទារសិទ្ធិមនុស្សដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពដល់សហគមន៍ទូទៅ។

- *សកម្មភាព ៣.៦. ការពង្រឹងទំនាក់ទំនងជាមួយ និងក្នុងចំណោមអ្នកទទួលផល*

ម.ស.ម.ក នឹងជ្រើសរើសអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានតាមសហគមន៍នានាក្នុងនីតិវិធីសាមញ្ញដែលនឹងទទួលបានការពង្រឹងសមត្ថភាព និងបំពាក់បំប៉នតាមរយៈកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលឱ្យយល់ដឹងពីសិទ្ធិរបស់សហគមន៍ពួកគេថែមទៀតដោយមានការគាំទ្រពី ម.ស.ម.ក។ នេះនឹងអាចឱ្យ ម.ស.ម.ក កសាងទំនាក់ទំនងជាមួយសហគមន៍បានរឹងមាំយូរអង្វែងជានិរន្តរ៍ ហើយក៏ជាការឆ្លើយតបបានប្រសើរទៅនឹងតម្រូវការបន្ទាន់នៅថ្នាក់មូលដ្ឋានផងដែរ។

- *សកម្មភាព ៣.៧. ការការពារអ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកការពារសិទ្ធិមនុស្សជាអ្នកស្រឡាញ់ភេទដូចគ្នា*

ម.ស.ម.ក នឹងបន្តចូលរួមឱ្យសកម្មជាមួយអ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងជាអ្នកស្រឡាញ់ភេទដូចគ្នាដើម្បីបង្កើតបណ្តាញដែលបង្កើនធនធាន និងពង្រឹងសមត្ថភាពដល់បុគ្គលនិងសហគមន៍ពាក់ព័ន្ធ។ យន្តការការពារអ្នកការពារសិទ្ធិមនុស្សមានបរិយាយពិស្តារនៅផ្នែក ៤.១ ដែលមានលើកឡើងអ្នកដែលត្រូវនឹងលក្ខខណ្ឌជាអ្នកការពារសិទ្ធិមនុស្ស។

## ៤.៤. វិស័យការងារស្នូលទី៤ – ធុរកិច្ច និងសិទ្ធិមនុស្ស

### *៤.៤.១. គោលដៅ លទ្ធផល និងសកម្មភាព*

គោលដៅរួមក្នុងវិស័យការងារស្នូលទី៤ គឺ ៖

- ពង្រឹងការការពារ ការគោរព និងការផ្តល់សំណងផ្នែកសិទ្ធិមនុស្សពីសំណាក់រដ្ឋាភិបាល និងតួអង្គសាជីវកម្មទាក់ទងនឹងធុរកិច្ច និងសិទ្ធិមនុស្ស

នៅក្នុងវិស័យការងារស្នូលទី ៤ ម.ស.ម.ក មានគោលបំណងសម្រេចនូវលទ្ធផលដូចខាងក្រោមៈ

- កាត់បន្ថយការបណ្តេញចេញដោយបង្ខំដោយតួអង្គសាជីវកម្មតាមតំបន់គោលដៅ
- រដ្ឋាភិបាល និងក្រុមហ៊ុនសាជីវកម្មយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួនក្រោមគោលការណ៍ណែនាំ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ជាពិសេសទាក់ទងនឹងសិទ្ធិដីធ្លី និងកម្មសិទ្ធិ ដោយបញ្ចូលកាតព្វកិច្ចទាំងនេះទៅក្នុងគោលនយោបាយរបស់ពួកគេ
- ការលើកកម្ពស់ និងការការពារទៅលើសិទ្ធិផ្សេងៗទៀតទាក់ទងនឹងប្រតិបត្តិការរបស់ធុរកិច្ច ដូចជាការលើកកម្ពស់សិទ្ធិការងាររបស់កម្មករនិយោជិតជាដើម។

- *សកម្មភាព ៤.១. បង្កើនចំណេះដឹងក្នុងចំណោមរដ្ឋាភិបាល និងក្រុមហ៊ុនសាជីវកម្ម*

ម.ស.ម.ក នឹងដោះស្រាយលើចំណុចខ្វះខាតទាក់ទងនឹងការយល់ដឹងរបស់រដ្ឋាភិបាល និងក្រុមហ៊ុនសាជីវកម្មអំពីតួនាទីរបស់ពួកគេក្នុងការការពារ ការគោរព និងការដោះស្រាយបញ្ហាសិទ្ធិមនុស្សទាក់ទងនឹងសកម្មភាពធុរកិច្ច តាមរយៈវិធីសាស្ត្រកៀរគរឱ្យមានការចូលរួមពីសំណាក់រដ្ឋាភិបាល និងក្រុមហ៊ុនសាជីវកម្ម ដែលលើកឡើងពីយុទ្ធសាស្ត្រកៀរគរការចូលរួមពីស្ថាប័ននានាដែលពាក់ព័ន្ធក្នុងការរំលោភបំពានសិទ្ធិមនុស្ស។

វិធីសាស្ត្រនេះនឹងលើកឡើងនូវយុទ្ធសាស្ត្រដែលត្រូវបញ្ចូលក្នុងគម្រោងនានាដើម្បីសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

- ការចូលរួមពីក្រុមហ៊ុនសាជីវកម្ម
  - លើកកម្ពស់ការយល់ដឹង ការអប់រំ ឬការបណ្តុះបណ្តាលដើម្បីគាំទ្រដល់ការប្រតិបត្តិដោយស្ម័គ្រចិត្តពីសំណាក់តួអង្គសាជីវកម្មតាមគោលការណ៍ណែនាំ អ.ស.ប ទាក់ទងនឹងការគោរព ការការពារ និងផ្តល់ដំណោះស្រាយក្នុងករណីចាំបាច់
  - ការសម្របសម្រួល និងការជំរុញឱ្យមានការគោរពតាមគោលការណ៍ណែនាំ អ.ស.ប តាមរយៈកិច្ចសន្ទនារវាងបុគ្គលរងផលប៉ះពាល់ ក្នុងនោះមានក្រុមហ៊ុន អាជ្ញាធរ និងសហគមន៍នានា។
- ការចូលរួមពីរដ្ឋាភិបាល
  - លើកកម្ពស់ការយល់ដឹង ការអប់រំ និងការបណ្តុះបណ្តាលដើម្បីឱ្យរដ្ឋាភិបាលបំពេញកាតព្វកិច្ចរបស់ខ្លួនទាក់ទងនឹងការការពារសិទ្ធិមនុស្សស្របតាមគោលការណ៍ណែនាំ អ.ស.ប និងជានាផ្តល់ដំណោះស្រាយក្នុងករណីចាំបាច់។

- *សកម្មភាព ៤.២. បន្តគាំទ្រសហជីព និងថ្នាក់ដឹកនាំសហជីពក្នុងការការពារសិទ្ធិរបស់កម្មករ*

តម្រូវការខាងការគាំទ្រ និងការពង្រឹងសមត្ថភាពថ្នាក់ដឹកនាំសហជីពដើម្បីតស៊ូមតិជាមួយម្ចាស់ក្រុមហ៊ុននឹងនៅតែមានសារៈសំខាន់ ដែលតម្រូវការជំនួយនេះទំនងកើនឡើង ហើយ ម.ស.ម.ក នឹងជួយទៅតាមទំហំមូលនិធិ

- *សកម្មភាព ៤.៣. បង្កើនផលជះនៃការអប់រំ និងសកម្មភាពពង្រឹងភាពអង់អាចក្លាហាន*

វិស័យការងារស្នូលទី៤ នឹងផ្តោតលើការបង្កើនចំណេះដឹងដល់បុគ្គល និងសហគមន៍ដែលរងផលប៉ះពាល់អំពីធុរកិច្ច និងសិទ្ធិមនុស្ស ព្រមទាំងពង្រឹងសមត្ថភាពបុគ្គលដែលសិទ្ធិរបស់ពួកគេរងការរំលោភបំពាន ដើម្បីតស៊ូមតិជាមួយអាជ្ញាធរឬក្រុមហ៊ុនសាជីវកម្មដោយខ្លួនពួកគាត់ផ្ទាល់។ អ្នកទទួលផលមួយចំនួនដែលប្រឈមនឹងការរំលោភបំពានសិទ្ធិមនុស្សជាក់លាក់ នឹងត្រូវបានជ្រើសរើសឱ្យចូលរួមរៀនសូត្រ និងចូលរួមក្នុងសកម្មភាពនានានៅក្នុងវិស័យការងារស្នូលទី៤។

- *សកម្មភាព ៤.៤. សហការក្នុងភាពជាដៃគូដើម្បីសម្រេចលទ្ធផលដោយប្រសិទ្ធភាពនៅថ្នាក់សហគមន៍*

ម.ស.ម.ក នឹងបន្តសហការជាមួយសង្គមស៊ីវិលដែលធ្វើសកម្មភាពនៅមូលដ្ឋាន បង្កើនទំនាក់ទំនងរឹងមាំជាមួយសហគមន៍ និងផ្តល់សេវាបន្ថែម។

- *សកម្មភាព ៤.៥. រក្សាទំនាក់ទំនងរឹងមាំជាមួយសហគមន៍ទទួលផល*

ម.ស.ម.ក នឹងជ្រើសរើសអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានពីសហគមន៍នានាតាមនីតិវិធីសាមញ្ញ ដែលនឹងត្រូវទទួលបានការពង្រឹងសមត្ថភាពបន្ថែមអំពីសិទ្ធិរបស់សហគមន៍របស់ខ្លួនបន្ថែមទៀត ក្រោមការគាំទ្រពី ម.ស.ម.ក ឧទាហរណ៍ដូចជាតាមរយៈកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលជាដើម។

- *សកម្មភាព ៤.៦. ការការពារអ្នកការពារសិទ្ធិមនុស្សក្នុងវិស័យធុរកិច្ច*

ម.ស.ម.ក នឹងបន្តចូលរួមឱ្យបានសកម្មជាមួយអ្នកការពារសិទ្ធិមនុស្សក្នុងវិស័យធុរកិច្ចក្នុងការបង្កើតបណ្តាញដែលជាការបង្កើនធនធាននិងការពង្រឹងសមត្ថភាពដល់បុគ្គលនិងសហគមន៍ពាក់ព័ន្ធ។ យន្តការការពារអ្នកការពារសិទ្ធិមនុស្សមានបរិយាយនៅផ្នែក ៤.១ ដែលមានលើកឡើងអំពីអ្នកដែលត្រូវនឹងលក្ខខណ្ឌជាអ្នកការពារសិទ្ធិមនុស្ស ។

## ៤.៥ វិស័យការងារស្នូលទី៥ – ការចូលរួមរបស់ពលរដ្ឋ និងកំណែទម្រង់

### *៤.៥.១. គោលដៅ លទ្ធផល និងសកម្មភាព*

គោលដៅរួមនៃវិស័យការងារស្នូលទី ៥ គឺ ៖

- ពលរដ្ឋចូលរួមយ៉ាងសកម្មក្នុងលម្អប្រជាធិបតេយ្យ ការអនុវត្តសិទ្ធិមនុស្សរបស់ខ្លួនដោយពុំមានការភ័យខ្លាចការយាយី ឬការរើសអើង។

សេចក្តីរំពឹងលទ្ធផលកម្រិតខ្ពស់ នោះគឺ

- ពលរដ្ឋយល់ដឹងអំពីស្ថានភាពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅកម្ពុជា និងទទួលបានការលើកទឹកចិត្តឱ្យចាប់អារម្មណ៍អំពីស្ថានភាពសិទ្ធិមនុស្សបន្ថែមទៀត
- ពលរដ្ឋពីក្រុមគោលដៅត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងលម្អប្រជាធិបតេយ្យឱ្យកាន់តែច្រើនឡើងៗ។

ក្នុងអំឡុងពេលនៃផែនការយុទ្ធសាស្ត្រមុន ការយល់ដឹងរបស់ពលរដ្ឋកម្ពុជាអំពីសេរីភាពមូលដ្ឋានមានការធ្លាក់ចុះស្របពេលដែលសិទ្ធិមនុស្សបានធ្លាក់ទ្រុឌទ្រោម។

ហេតុដូចនេះ ចាំបាច់ត្រូវតែពង្រឹងការយល់ដឹងដល់សាធារណជនអំពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ហើយនិងការវិវឌ្ឍក្របខ័ណ្ឌច្បាប់ និងសកម្មភាពនានារបស់អាជ្ញាធរ។

ម.ស.ម.ក មានគោលបំណងសម្រេចនូវលទ្ធផលនៅក្នុងវិស័យការងារស្នូលទី៥ តាមរយៈសកម្មភាពលើកកម្ពស់ការយល់ដឹងនិងលើកកម្ពស់ស្មារតីប្រកបដោយប្រសិទ្ធភាព។ ម.ស.ម.ក នឹងប្រឹងប្រែងធ្វើយ៉ាងណាឱ្យពលរដ្ឋទូទៅមានការចាប់អារម្មណ៍លើបញ្ហាសិទ្ធិមនុស្ស និងលើកទឹកចិត្តឱ្យពលរដ្ឋចូលរួមយ៉ាងសកម្ម ពីព្រោះសិទ្ធិមនុស្សមានឥទ្ធិពលលើផ្លូវចិត្តរបស់មនុស្សគ្រប់រូប។

គោលដៅក្រុមអ្នកទទួលផលនៅក្នុងវិស័យការងារស្នូលទី៥ មានដូចជា ៖

- ពលរដ្ឋកម្ពុជាទូទៅ និងក្រុមសំខាន់ជាក់លាក់មួយចំនួនដូចជា យុវជន និងបុគ្គលដែលមានចំណាប់អារម្មណ៍លើទិដ្ឋភាពសិទ្ធិមនុស្សក្នុងវិស័យជាក់លាក់មួយចំនួនដូចជា ស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា ជនជាតិដើមភាគតិច និងបុគ្គលរងផលប៉ះពាល់ដោយសារបញ្ហាដីធ្លីនិងសិទ្ធិកាន់កាប់
- សហាគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា ក្នុងនោះរួមមាន អ្នកការពារសិទ្ធិមនុស្ស សកម្មជន និងអង្គការសង្គមស៊ីវិល ហើយនិងអង្គការអន្តរជាតិ។

- *សកម្មភាព ៥.១. ការបង្កើតពហុមធ្យោបាយទំនាក់ទំនងឱ្យបានទូលំទូលាយ និងការចូលរួមតាមជម្រើសជាច្រើន*

ម.ស.ម.ក បង្កើតមធ្យោបាយទំនាក់ទំនងទូលំទូលាយ និងការចូលរួមតាមជម្រើសជាច្រើន ដែលលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សក្នុងចំណោមពលរដ្ឋនៅកម្ពុជា និងក្រុមគោលដៅជាក់លាក់មួយចំនួន ព្រមទាំងលើកទឹកចិត្តឱ្យពួកគាត់ចូលរួមក្នុងលម្ហសេរីភាពទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស។

មធ្យោបាយនេះរួមមាន ៖

- ពង្រឹង និងពង្រីកកម្មវិធីវិទ្យុតាមយុទ្ធសាស្ត្រនៃប្រព័ន្ធផ្សព្វផ្សាយដោយទំលំទូលាយ
- បង្កើនសកម្មភាពលើអ៊ីនធឺណិតនិងអនុវត្តយុទ្ធសាស្ត្រប្រព័ន្ធផ្សព្វផ្សាយសង្គមឱ្យមានប្រសិទ្ធភាព
- ផ្តល់ទីកន្លែងសម្រាប់រៀបចំកម្មវិធីបែបនវានុវត្តន៍នានា

មធ្យោបាយនេះនឹងអាចឱ្យ ម.ស.ម.ក អនុវត្តជាយុទ្ធសាស្ត្រនូវការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួននិងក្នុងការចែករំលែកសារ ដើម្បីធានាឱ្យគោលបំណងជាយុទ្ធសាស្ត្រស្នូលរបស់ ម.ស.ម.ក ក្លាយជាមូលដ្ឋានសំខាន់នៃទំនាក់ទំនង។

## ៤.៦. វិស័យការងារស្នូលទី៦ – ការស្រាវជ្រាវ ឥស្ស៊ូមតិ និងគោលនយោបាយ

### *៤.១.១. គោលដៅ លទ្ធផល និងសកម្មភាព*

គោលដៅរួមនៃវិស័យការងារស្នូលទី៦ មានដូចជា ៖

- រដ្ឋាភិបាល និងតួអង្គផ្សេងទៀតបំពេញតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារ និងគោរពសិទ្ធិមនុស្ស

លទ្ធផលខាងក្រោមនឹងគាំទ្រដល់ទិសដៅនេះ ៖

- អ្នកតាក់តែងគោលនយោបាយ រួមទាំងរដ្ឋាភិបាលអាចដឹងថាតើសកម្មភាពណាខ្លះស្របទៅនឹងក្របខ័ណ្ឌច្បាប់កម្ពុជា និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

- អ្នកតាក់តែងគោលនយោបាយ ក្នុងនោះរួមទាំងរដ្ឋាភិបាលយល់ដឹងអំពីវិសាលភាព និងប្រភេទនៃការរំលោភសិទ្ធិមនុស្សនៅកម្ពុជា និងលក្ខខណ្ឌក្នុងការផ្តល់សំណាងដល់ប្រជាពលរដ្ឋ។

វិស័យការងារស្នូលទី៦ សម្រេចនូវគោលដៅ និងលទ្ធផលទាំងនេះតាមរយៈសកម្មភាពខាងក្រោម ៖

- *សកម្មភាព ៦.១. បន្តការតស៊ូមតិផ្អែកលើភ័ស្តុតាង*

វិស័យការងារស្នូលទី៦ មានគោលបំណងកំណត់យកការស្រាវជ្រាវ តស៊ូមតិ និងគោលនយោបាយជាការងារនាំមុខសម្រាប់បញ្ចូលទៅក្នុងរបៀបវារៈការងាររបស់ ម.ស.ម.ក។

នៅក្រោមវិស័យការងារស្នូលទី៦ នឹងត្រូវអនុវត្តនៅក្នុងករណីមានការរំលោភបំពានសិទ្ធិមនុស្សកើតឡើងភ្លាមៗ និងសំខាន់ តាមរយៈការគាំទ្រដល់គម្រោងដែលកំពុងអនុវត្តសកម្មភាពជាធរមានក្នុងការងារផ្នែកស្រាវជ្រាវ តស៊ូមតិ និងគោលនយោបាយផ្សេងទៀត ហើយនឹងអនុវត្តដោយឯករាជ្យ ដូចជាការវិភាគច្បាប់ឬសេចក្តីព្រាងច្បាប់ ព្រមទាំងផ្តោតការយកចិត្តទុកដាក់លើចំណុចអាទិភាពខ្លាំង ជាជាងលើវិស័យ ការងារមិនសូវសំខាន់។

- *សកម្មភាព ៦.២. ការពង្រឹងនិងការគាំទ្រដល់ក្រុមការងារផ្នែកវិភាគច្បាប់*

ក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រចុងក្រោយនេះ ច្បាប់មួយចំនួនធំដែលប៉ះពាល់ដល់សិទ្ធមនុស្ស ត្រូវបាន ម.ស.ម.ក វិភាគផ្អែកលើភ័ស្តុតាងនិងមានលក្ខណៈស៊ីជម្រៅថែមទៀត។

កន្លងមក ក្រុមការងារទីប្រឹក្សាច្បាប់នៅ ម.ស.ម.ក ត្រូវទទួលបន្ទុកខ្លាំងលើការវិភាគច្បាប់ដើម្បីឆ្លើយតបទៅនឹងព្រឹត្តិការណ៍ឱ្យបានទាន់ពេលវេលា។

ដើម្បីធានាការឆ្លើយតបមាននិរន្តរភាព និងគុណភាព ម.ស.ម.ក មានគោលបំណងពង្រឹងក្រុមការងារទីប្រឹក្សាច្បាប់។ ឆ្លើយតបនឹងចំណុចនេះ ម.ស.ម.ក មានគោលបំណងបញ្ចូលសមាសភាពទីប្រឹក្សាច្បាប់ជនជាតិកម្ពុជា និងជំនួយការីទៅក្នុងក្រុមការងារវិភាគច្បាប់។

- *សកម្មភាព ៦.៣. ការសម្របសម្រួលជាមួយអង្គការដែលមានចក្ខុវិស័យប្រហាក់ប្រហែលគ្នា*

ដើម្បីបង្កើនសំឡេងបន្ថែមទៅលើការវិភាគច្បាប់របស់ ម.ស.ម.ក គឺតម្រូវឱ្យមានការឆ្លើយតបតាមវិស័យ។ ម.ស.ម.ក មានគោលបំណងសហការជាមួយអង្គការនានាដែលមានចក្ខុវិស័យប្រហាក់ប្រហែលគ្នាដើម្បីសម្របសម្រួលការឆ្លើយតបនេះដែលនឹងមានធនធានច្បាប់ទូលំទូលាយនៅក្នុងវិស័យនោះដើម្បីឱ្យប្រជាពលរដ្ឋប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាសំខាន់ៗ និងចាំបាច់។

- *សកម្មភាព ៦.៤. ការបង្កើតប្រតិទិនប្រចាំឆ្នាំបញ្ចូលរបាយការណ៍ ការវិភាគ និងការតស៊ូមតិ*

ដើម្បីគាំទ្រវិធីសាស្ត្រជាយុទ្ធសាស្ត្រក្នុងការស្រាវជ្រាវ វិភាគនិងតស៊ូមតិ ប្រតិទិនប្រចាំឆ្នាំនឹងកំណត់ដូចខាងក្រោម ៖

  - របាយការណ៍សម្រាប់ម្ចាស់ជំនួយ
  - របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តគម្រោង
  - ការស្រាវជ្រាវ ការវិភាគ និងការតស៊ូមតិផ្តោតលើបញ្ហាអាទិភាពសំខាន់ៗ។

ប្រតិទិននេះនឹងបង្ហាញពីរបៀបនៃការចាត់ចែងធនធាននានារបស់ ម.ស.ម.ក អោយស្របជាមួយទំហំការងារសម្រាប់ឆ្នាំខាងមុខ ហើយនឹងជួយកំណត់លើអាទិភាពការងារ និងការចរចាជាមួយម្ចាស់ជំនួយទាក់ទងនឹងទំហំការងារក្នុងការផលិតរបាយការណ៍។

ប្រតិទិននេះនឹងបង្ហាញជាក់លាក់ និងច្បាស់លាស់អំពីភាពអាស្រ័យគ្នាទៅវិញទៅមករវាងសកម្មភាពនានានៅក្នុងវិស័យការងារស្នូលផ្សេងៗ រួមទាំងទំនាក់ទំនងរវាងការតស៊ូមតិ និងការគាំទ្រដល់ការស្រាវជ្រាវ និងការវិភាគ។ នេះក៏នឹងនាំឱ្យមានការវិភាគជាយុទ្ធសាស្ត្រ និងការរៀបចំផែនការក្នុងការផ្តល់ព័ត៌មានដើម្បីជាមូលដ្ឋានក្នុងការសេចក្តីសម្រេចចិត្តទាក់ទងនឹងការស្រាវជ្រាវ ការវិភាគ និងគោលនយោបាយផងដែរ៕

---ចប់---